អង្គការយើងឈ្មោះ**ACRS** ជួយជាពិសេសដល់ជនភៀសខ្លួន ជនអន្តោប្រវេសន៏ និងជនជាតិអាស៊ីទាំងឡាយ ដែលកើតនៅក្នុងសហរដ្ឋអាមេរិក ដែលរស់នៅក្នុងតំបន់យើងខោនធី ហើយដែលមានប្រាក់ចំណូលតិច។ អង្គការ **ACRS** មានបេសកកម្មចំបងគឺ ជួយលើកដំកើងយុត្តិធម៍សង្គម និងសុខមាលភាពសង្គម។ ហើយជួយបង្កើនថាមពលដល់បុគ្គល ដល់គ្រួសារ និងសហគមន៏ នៃជនជាតិអាស៊ីយើង ដោយរាប់បញ្ចូលទាំង ជនភៀសខ្លួន ជនអន្តោប្រវេសន៏ និងជនដែលកើតនៅស្រុកអាមេរិកនេះផងដែរ។ ការជួយបង្កើនថាមពលនេះ នឹងត្រូវធ្វើឡើង ដោយធ្វើឲ្យចំរើនលូតលាស់ ផ្តល់ជំនួយ និងជួយការពារផលប្រយោជន៏ ដើម្បីបញ្ចូលនូវរបៀប ថ្មី ជួយដល់សហគមន៏យើង ដោយពហុភាសា និងពហុវប្បធម៌។ បងប្អូនជនជាតិផ្សេងៗ នឹងត្រូវជួយដោយ បុគ្គលិកអ្នកធ្វើការ ដែលចេះនិយាយភាសា ស្គាល់ទំនៀមទម្លាប់របស់ជនជាតិនោះ។ អង្គការ **ACRS** យើង មានកម្មវិធីដូចខាងក្រោមនេះ សំរាប់ជួយដល់បងប្អូនជនជាតិអាស៊ី ដើម្បីកែលំអជីវភាពឲ្យបានកាន់តែប្រសើរ :

១- កម្មវិធីជួយដល់ជនចាស់ជរា និងជនពេញវ៉ៃ (ផ្តល់ពត៌មានផ្សេងៗ ជួយដោះ ស្រាយបញ្ហាផ្សេងៗ ជួយផ្តល់ការមើលថែទាំដល់ជនចាស់ជរា ដែលមានអាយុ ៦០ឆ្នាំឡើងទៅ និងជនពេញវ៉ៃ ដែល មានភាពពិការណាមួយ)។

២- កម្មវិធីជួយដល់កុមារ យុវជន និងក្រុមគ្រួសារ (ផ្តល់ការណែនាំអប់រំ ជួយដោះ ស្រាយបញ្ហា ផ្សេងៗ ជួយអប់រំដល់ឪពុកម្តាយ ជួយធ្វើឲ្យយុវជនមានសកម្មភាពផ្សេងៗ ជួយបង្កើតឲ្យមានជាក្រុម គាំទ្រគ្នា ( support group ) ជាដើម)។

៣- កម្មវិធីជួយដល់អ្នកមានជំងឺខាងផ្លូវចិត្ត សតិអារម្មណ៏មិនល្អ (ការព្យាបាល ធ្វើការវាយតម្លៃខាង វិកលចរិត ផ្តល់ថ្នាំព្យាបាល ជួយដោះស្រាយបញ្ហាផ្សេងៗ)។

៤- ជួយផ្តល់យោបល់ណែនាំ និងផ្តល់ការអប់រំបង្រៀន(ផ្តល់យោបល់និងបង្រៀនដល់សហគមន៏ផ្សេងៗ)

៥- កម្មវិធីជួយដល់អ្នករងគ្រោះដោយភាពកំរោលក្នុងគ្រួសារ និងការអប់រំ(ព្យាបាលដល់អ្នករងគ្រោះ ជួយអ្នករងគ្រោះក្នុងទំនាក់ទំនងជាមួយអង្គការផ្សេងទៀត ជួយអប់រំណែនាំដល់សហគមន៏។

៦- កម្មវិធីជួយផ្តល់ម្ហូបអាហារដល់ជនចាស់ព្រឹទ្ធាចារ្យ ផ្តល់ម្ហូបអាហារនៅពេលមាន ភាពអាស័ន្ន និង មានចែកហ្វូតបាំងរាល់អាទិត្យទៀតផង។

៧- កម្មវិធីព្យាបាលដល់អ្នកប្រើគ្រឿងញៀន(ជួយណែនាំអប់រំ ជួយបង្រៀនដល់សហគមន៏ ជួយបង្កើតឲ្យ មានជាក្រុមគាំទ្រគ្នា( support group )ជាដើម)។

៨- កម្មវិធីជួយផ្តល់ពត៌មាន Information និងជួយបញ្ជូនបន្ត Referral ។

៩- កម្មវិធីជួយផ្តល់យោបល់ខាងផ្លូវច្បាប់(ជួយដោយមិនគិតថ្លៃ ជួយបើកសិក្ខាសាលាបង្រៀនច្បាប់)។

១០- កម្មវិធីជួយចូលសញ្ជាតិ (មានបើកថ្នាក់បង្រៀនភាសាអង់គ្លេស ថ្នាក់រៀនចូល សញ្ជាតិជួយផ្តល់ពត៌ មាននិងដោះស្រាយរឿងរាវដែលទាក់ទងខាងអន្តោប្រវេសន៏)។

១១- កម្មវិធីជួយដែលទាក់ទងក្នុងរឿងរកការងារធ្វើ(ជួយឲ្យយោបល់ ណែនាំអំពីរឿងការងារមានបើកថ្នាក់ បង្រៀនភាសាអង់គ្លេស មានជួយរកកាងារ បញ្ជូនឲ្យទៅរៀនមុខវិជ្ជាផ្សេងៗ

បើសិនជាលោកអ្នកនាងចង់បានពត៌មានផ្សេងៗបន្ថែមទៀតសូមទូរស័ព្ទមកលេខ: (២០៦) ៦៩៥-៧៦០០